ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ០០១.ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០០

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងក្រុមជាងសំណង់

អនុលោមទៅតាមប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុនស៊ីក្សាគំរោងប្លង់ និង សាងសង់ និង ដើម្បីគ្រប់គ្រង អោយមានប្រសិទ្ធភាពការងារសាងសង់ ដែលអនុវត្តដោយក្រុមជាងសំណង់នៅតាមបណ្តា ខេត្ត ក្រុង ដែលបច្ចុប្បន្ននេះក្រុមជាងសំណង់ទាំងនេះប្រកបរបរអាជីវកម្មសាងសង់តាមទ្រង់ទ្រាយអាជីវកម្មតូច និង មិនទាន់មានច្បាប់អនុញ្ញាតពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំដូចតទៅ :

## I - សិទ្ធិរបស់ក្រុមជាងសំណង់

ការប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់ ត្រូវបានប្រគល់សិទ្ធិអោយអនុវត្តការងារតាមការកំណត់ និង មុខជំនាញដូចខាងក្រោម ហើយដែលមានទំហំបច្ចេកទេសមិនលើសពីកំរិតកំណត់ដូចតទៅ :

- ផ្ទៃក្រឡាសំណង់សរុប 80 ម៉ែត្រទ្វេគុណ
- ផ្ទៃក្រឡាសំណង់ ដែលត្រូវសង់ថ្មីបន្ត ឬពង្រីកបន្ថែម ត្រូវបូកបញ្ចូលនឹងផ្ទៃក្រឡាសំណង់ចាស់មានស្រាប់
- ផ្ទៃក្រឡាសំណង់ត្រូវគិតបញ្ចូលគ្នា ចំពោះសំណង់ដែលមានគ្រឿងផ្គុំជាប់គ្នា ទោះបីមានកម្មសិទ្ធិដោយឡែកពីគ្នា ឬពេលវេលានៃការអនុញ្ញាតអោយសាងសង់ខុសគ្នាក៏ដោយ
- កំពស់អគារមួយជាន់ ( ជាន់ផ្ទាល់ដី )
- អគារពុំមានត្រៀមលក្ខណៈសង់បន្ថែមច្រើនជាន់
- សំណង់អគារពុំស្ថិតនៅតំបន់ដី បាក់ស្រុត តំបន់ដីមានកំរិតទ្រខ្សោយ
- ធ្នឹមកំរាល ធ្នឹមទ្រជ្រុង១ មានប្រវែង 4 ម៉ែត្រ ប្រែហ្វមគ្រោងដំបូលមានប្រវែង 8 ម៉ែត្រ ធ្នឹមអណ្តែតមាន ប្រវែង 1,50 ម៉ែត្រ
- អាងកប់ដី ដែលមានចំណុះ 10 ម៉ែត្រត្រីគុណ អាងទឹកខ្ពស់ពីដី 4 ម៉ែត្រ ដែលមានចំណុះ 8 ម៉ែត្រត្រីគុណ

- របងកំពស់ 2,5 ម៉ែត្រ គិតពីទីវ៉ូ ដីត្រង់ជើងរបង
- សំណង់ជាល់នៅឋានរបស់ប្រជាពលរដ្ឋធ្វើពីឈើ ( ដោយមិនគិតពីផ្ទៃក្រឡា និងកំពស់នៃសំណង់ )
- ម៉ៅការបន្ត ការងារជុសជុល និង សាងសង់ពី សហគ្រាស ក្រុមហ៊ុនសាងសង់នានា ដែលមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយមានការទទួលខុសត្រូវលើលក្ខណៈបច្ចេកទេសពីសហគ្រាស ក្រុមហ៊ុនសាងសង់នោះ

- ក្រុមជាងសំណង់ កាលណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចសុំតំឡើងឋានៈប្រភេទជាសហគ្រាស ក្រុមហ៊ុន សាងសង់បាន ដោយត្រូវធ្វើបែបបទស្នើសុំមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បី ពិនិត្យសំរេច ។

## II. សមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្ត ក្រុង

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មអោយដល់ក្រុមជាងសំណង់
- ចេញលិខិត បិទ ផ្អាក អាជីវកម្ម ក្រុមជាងសំណង់
- ស្រង់ស្ថិតិ សហគ្រាស ក្រុមហ៊ុនរួមទាំងក្រុមជាងសំណង់ និង ក្រុមជាងតាមមុខជំនាញ ដែលធ្វើអាជីវកម្មក្នុងមូលដ្ឋានរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ គ្រប់គ្រងសកម្មភាពអាជីវកម្ម
- ត្រូវផ្អាក ឬ បិទសកម្មភាពអាជីវកម្មរបស់ក្រុមជាងសំណង់ណា ដែលប្រកបអាជីវកម្មជុសជុល និងសាងសង់ គ្មានលិខិតអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬ ក្នុងករណីដែលក្រុមជាងសំណង់នោះមិនគោរពតាមការកំណត់ ការណែនាំ បទប្បញ្ញត្តិផ្សេងៗ ពីក្រសួង ស្ថាប័ន និង មន្ទីរខេត្ត ក្រុងបានសមត្ថកិច្ច ។

## III. ល័ក្ខខ័ណ្ឌសុំប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់

១- ប្រធានក្រុមជាងសំណង់ ដែលជាមេជាងសំណង់ត្រូវមានសញ្ជាតិខ្មែរ

២- ប្រធានក្រុមជាងសំណង់ត្រូវមកដាក់ពាក្យសុំប្រកបអាជីវកម្មដោយខ្លួនឯងផ្ទាល់

៣- នាមករណ៍របស់ក្រុមជាងសំណង់មិនអនុញ្ញាតអោយប្រើពាក្យថា សហគ្រាស ឬ ក្រុមហ៊ុនឡើយ

៤- ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥- ក្រុមជាងសំណង់ ត្រូវតំកល់ទុករបាយការណ៍ សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង តាមការណែនាំរបស់មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង

៦- ក្នុងករណីមានការផ្លាស់ប្តូររាស័យដ្ឋាន ឬ ប្រធានក្រុមជាងសំណង់ ត្រូវជូនដំណឹងមកមន្ទីររៀបចំដែន ដី

នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង យ៉ាងយូរ២សប្តាហ៍ក្រោយការផ្លាស់ប្តូរ ។

## IV- ទំរង់បែបបទ សុំប្រកបអាជីវកម្ម

- ពាក្យសុំប្រកបអាជីវកម្ម ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ប្រធានក្រុមជាងសំណង់ដោយមានបិទរូបថតទំហំ ៤ x ៦ ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ ជាង តាមមុខជំនាញ មានបិទរូបថត ៤ x ៦ ៤ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ របស់ប្រធានក្រុមជាងសំណង់ ដែលមានធ្វើនិត្យានុកូលកម្ម នៅសាលា ខេត្ត ក្រុង ៤ច្បាប់
- សេចក្តីប្រកាសពីភាពគ្មានទោសពៃរ៍ របស់ប្រធានក្រុមជាងសំណង់ ៤ច្បាប់
- លក្ខន្តិកៈរបស់ក្រុមជាងសំណង់ ៤ច្បាប់
- កិច្ចសន្យារវាងក្រុមជាងសំណង់ និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដែលចេញលិខិតអនុញ្ញាតអោយប្រកបអាជីវកម្ម ៤ច្បាប់
- បញ្ជីរាយឈ្មោះជាងសំណង់តាមផ្នែកជំនាញ និង អង្គការលេខ របស់ក្រុមជាងសំណង់ ៤ច្បាប់
- ឯកសារស្នាដៃ (បើមាន) ២ច្បាប់
- បញ្ជីគ្រឿងចក្រសំណង់ (បើមាន) និង សំភារៈបរិក្ខារ ៤ច្បាប់
- ឯកសារធនាគារ (បើមាន) ១ច្បាប់
- បង្កាន់ដៃបង់ពន្ធ (ប័ណ្ណប៉ាតង់) ១ច្បាប់
- វិញ្ញាបនប័ត្រ ចុះបញ្ជីពាណិជ្ជកម្ម (បើមាន) ១ច្បាប់

រាល់ការបំពេញបែបបទដូចមានចែងក្នុងចំណុច IV ខាងលើ ត្រូវបំពេញតាមសំណុំឯកសារសុំប្រកបអាជីវកម្ម ដូចមានជូនភ្ជាប់ជាមួយ ។

## V- សុពលភាព នៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម

លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដល់ក្រុមជាងសំណង់ មានសុពលភាពបីឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ហើយក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាពក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតជាថ្មី ពីមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដោយភ្ជាប់មកជាមួយនូវ លិខិត អនុញ្ញាតចាស់ និង បង្កាន់ដៃបង់ ពន្ធអាករជាថ្មី ។

ទទួលបានសារាចរណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាព ។

អ៊ឹម ឈុនលឹម

ចម្លងជូន ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន
- សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរ ដ.ន.សសខេត្ត ក្រុង
- ឯកសារកាលប្បវត្តិ